ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៧៧៨.អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់វេទិកាសម្ព័ន្ធសង្គមស៊ីវិល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជ រដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសាឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦ /០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**មាត្រា ១ .—**

ត្រូវបានបង្កើតវេទិកាសម្ព័ន្ធសង្គមស៊ីវិល ដែលមានអក្សរកាត់ "**វ.ស.ស.**" ដើម្បីប្រមូលផ្តុំទស្សនៈ មតិយោបល់ ពីសំណាក់ បញ្ញវន្ត ក្រុមស្រាវជ្រាវ បណ្ឌិតសភាចារ្យ សង្គមស៊ីវិល តាមរយៈកិច្ចពិភាក្សា ស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រដែលអាចលើកជាសំណើគោលនយោបាយថ្មីៗ សម្រាប់បម្រើផលប្រយោជន៍សាធារណៈ តាមគោលការណ៍ស្ម័គ្រចិត្ត ។

**មាត្រា ២ .—**

**វ.ស.ស.**មានទិសដៅ និងគោលបំណងដូចតទៅៈ

-ជាទស្សន ទូលំទូលាយសំរាប់កិច្ចពិភាក្សាលើកសំណើគោលនយោបាយថ្មីៗ

- ចងក្រងនិងរៀបចំគំនិត និងយោបល់ផ្សេងៗ និងប្រែក្លាយគំនិតយោបល់ទាំងនោះឲ្យទៅជាសំណើគោលនយោបាយមួយដែលអាចអនុវត្តបាន និងមានសុក្រឹតភាព តាមរយៈការស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ និងកិច្ចពិភាក្សាពិគ្រោះយោបល់ផ្ទៃក្នុង

- ផ្តល់ជាវេទិកាប្រកបដោយស្ថាបនាដើម្បីផ្លាស់ប្តូរមតិ យោបល់ គំនិត ជាមួយតួអង្គពាក់ព័ន្ធទាំងឡាយក្នុងដំណើរការលើកសំណើគោលនយោបាយថ្មីៗ

-សំរបសំរួល និងធ្វើសុខដុមនីយកម្មបណ្តាញនានាដើម្បីឆ្លើយតបទៅនិងបញ្ហាសំខាន់ៗក្នុងស្រុក តំបន់ និង អន្តរជាតិ

**មាត្រា ៣ .-**

**ឧ.ស.ស.**មានតួនាទីនិងភារកិច្ចដូចតទៅ៖

-រៀបចំវេទិកា អំពីបញ្ហានានាដែលកម្ពុជាកំពុងប្រឈម

-ប្រមូលផ្តុំមតិយោបល់ តាមវិធីសាស្ត្រស្រាវជ្រាវ និងពិភាក្សាដេញដោល ពីបញ្ញវន្ត ក្រុមស្រាវជ្រាវ បណ្ឌិតសភាចារ្យ ទាំងក្នុង និងក្រៅប្រទេស ដើម្បីចងក្រង និងបោះពុម្ពផ្សព្វផ្សាយ

- ចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលដើម្បីកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់ជីវភាពប្រជាពលរដ្ឋកម្ពុជា ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល

- ចូលរួមចំណែកក្នុងការពង្រឹងនីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ សេរីភាពបញ្ចេញមតិក្នុងគ្របខ័ណ្ឌច្បាប់

- ចូលរួមចំណែកផ្សព្វផ្សាយទស្សនៈ មតិយោបល់ និងសកម្មភាពទាំងឡាយដែលមានគោលបំណងរក្សាសន្តិភាព ស្ថេរភាពនយោបាយ និងការអភិវឌ្ឍប្រកបដោយចិរភាព។

- បូកសរុបរបាយការណ៍ ទស្សនៈ និងលទ្ធផលជូនប្រមុខរាជរដ្ឋាភិបាល ។

**មាត្រា ៤ .-**

**ឧ.ស.ស.**មានក្រុមប្រឹក្សាភិបាលមួយដែលមានសមាសភាពតាមការចាំបាច់ ដែលត្រូវទទួលស្គាល់ដោយរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។ ក្រុមប្រឹក្សាភិបាលត្រូវដឹកនាំដោយប្រធានមួយរូប ។ សមាជិកនីមួយៗ មានតួនាទីផ្តល់យោបល់ បញ្ចេញគំនិត តាមរយៈការស្រាវជ្រាវ និងពិភាក្សាដេញដោលតាមបែបវិទ្យាសាស្ត្រដល់អគ្គលេខាធិការដ្ឋាន វ.ស.ស. ។

**មាត្រា ៥ .-**

**ឧ.ស.ស.**មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ ដឹកនាំដោយអគ្គលេខាធិការមួយរូប និងអមដោយអគ្គលេខាធិការរងមួយចំនួន ជាជំនួយការ។

អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ឬអនុក្រឹត្យ។

**មាត្រា ៦ .-**

អគ្គលេខាធិការដ្ឋាន **ឧ.ស.ស.** មានទីស្នាក់ការនៅទីស្តីការគណៈរដ្ឋមន្ត្រី។

អគ្គលេខាធិការដ្ឋាន **ឧ.ស.ស.**មានមន្ត្រីគ្របខណ្ឌមុខងារសាធារណៈ និងអាចជ្រើសរើសបុគ្គលិកជំនាញជាប់កិច្ចសន្យាតាមការចាំបាច់ ដើម្បីបម្រើការងារស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

**មាត្រា ៧ .-**

ប្រភពថវិការបស់ **ទ.ស.ស**.បានមកពីថវិការបស់ដៃគូរ និងសប្បុរសជនផ្សេងៗទៀត និងថវិការមួយផ្នែកតូចបានមកពីថវិការបស់ទីស្ដីការគណៈរដ្ឋមន្ត្រី ។ **ទ.ស.ស**.មានសិទ្ធិទទួល និងចាត់ចែងប្រើប្រាស់តាមនីតិវិធីច្បាប់ជាធរមាននូវធនធាន និងថវិកាពីដៃគូរផ្សេងៗទៀតសម្រាប់ដំណើរការការងាររបស់ខ្លួន។

**មាត្រា ៨ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៩ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីពាក់ព័ន្ធ និងប្រធានស្ថាប័នពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្ដីគោរពជម្រាបជូន
សម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**សុខ អាន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្ដម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ